

# ជំពូកទី ១៧

# នៅពេលកូនអ្នកធំឡើង

## នៅពេលដែលកូនរបស់អ្នកដឹងពិតប្រាកដថា ខ្លួនគេជាក្មេងពិការភ្នែក

កុមារតូចដែលពិការភ្នែកគិតថា មនុស្សគ្រប់គ្នារៀនអំពីព្រឹត្តិការណ៍ទាំងឡាយដូចរបៀបដែលគេបានរៀនអញ្ចឹងដែរ ។ គេមិនបានដឹងថាកុមារដទៃទៀតមានវិធីខុសប្លែកគ្នានៃការដឹង និងរៀនអំពីព្រឹត្តិការណ៍ទាំងឡាយឡើយ ។ ប៉ុន្តែនៅពេលគេធំបន្តិច កុមារដែលពិការភ្នែកចាប់ផ្តើមយល់ថាខ្លួនគេមានការខុសប្លែកពីអ្នកដទៃ ។

កុមារតូចដែលពិការភ្នែកគិតថាអ្នកដទៃមើលទៅរបស់របរដោយប្រើដៃដូចគេអញ្ចឹងដែរ ។







នៅពេលកុមារពិការភ្នែកមានអាយុប្រហែល 5 ឆ្នាំ គេចាប់ផ្តើមយល់ថាកុមារដទៃទៀតមិនត្រូវការស្ទាបអ្វីមួយដើម្បី "មើល" វាឡើយ ។




នៅពេលដែលក្មេងពិការភ្នែកចាប់ផ្តើមសម្គាល់ឃើញថា គេខុសពីក្មេងដទៃ គេអាចមានអារម្មណ៍ថ្មីដែលពុះកញ្ជ្រោលអំពីភាពខុសប្លែករបស់ខ្លួន ។ កុមារដែលពិការភ្នែក ឬ មិនអាចមើលឃើញច្បាស់មួយចំនួនមានអារម្មណ៍តូចចិត្តអំពីភាពខុសប្លែករបស់ខ្លួន ហើយក្មេងខ្លះទៀតខឹងសម្បារ ឬ ធុញថប់ ។

## ការជួយកូនឱ្យយល់ពីអារម្មណ៍របស់គេ

កុមារពិការភ្នែកជាច្រើនមានអារម្មណ៍តូចចិត្ត ខកចិត្ត និងសោកសៅ នៅពេលពួកគេសម្គាល់ដឹងថាខ្លួនឯងពិការភ្នែក ហើយមិនអាចធ្វើអ្វីៗទាំងឡាយដែលកុមារដទៃទៀតអាចធ្វើ ។ បើអ្នកជាសមាជិកនៃក្រុមឪពុកម្តាយដែលមានកូនពិការភ្នែក ឪពុកម្តាយឯទៀតប្រហែលជាអាចប្រាប់អ្នកពីរបៀបដែលពួកគាត់ឆ្លើយនឹងសំណួរកូនរបស់គាត់ ។ វាអាចជួយអ្នកក្នុងការជជែកអំពីការឆ្លើយនឹងសំណួររបស់កូនឱ្យបានមុន ធ្វើដូច្នេះអ្នកអាចត្រៀមជាស្រេចចំពោះសំណួររបស់កូន ។






កុមារពិការភ្នែកអាចសំដែងអារម្មណ៍យ៉ាងមានៈដោយទទូចថា គេចង់មើលឃើញ ឬ ថាគេនឹងអាចមើលឃើញនៅពេលគេធំឡើង ។ គេអាចដេញដោលសួរអ្នកថា ហេតុអ្វីបានជាគេពិការភ្នែក ។




កូនរបស់អ្នកអាចទៅជាមានកំហឹងខ្លាំង និងអាចសំដែងអាការៈខឹងសម្បាររបស់ខ្លួនតាមរយៈអាកប្បកិរិយា និងសំដែងឬកពារច្រឡើសបើសចំពោះក្រុមគ្រួសារ ។

នៅពេលអ្នកឆ្លើយនឹងសំណួររបស់កូន អ្នកត្រូវធ្វើឱ្យកូនទុកចិត្តខ្លួនឯងឡើងវិញ និងនិយាយសរសើរកូនចំពោះអ្វីៗទាំងអស់ដែលគេអាចធ្វើបាន ។ កូនរបស់អ្នកកាន់តែមានការងាយស្រួល ក្នុងការទទួលយកភាពពិការភ្នែករបស់ខ្លួន បើសិនជាគេដឹងថាអ្នកឈឺឆ្អាលយកចិត្តទុកដាក់ ហើយយល់ចិត្តរបស់គេ ។




ពេលកូនអ្នកនិយាយអំពីអារម្មណ៍ទាំងនេះ ចូរប្រាប់កូនថា អ្នកយល់ថាគេតូចចិត្ត ។ ចូរឱ្យកូនដឹងថាអ្នកយកចិត្តទុកដាក់អំពីអារម្មណ៍របស់គេ ។

## ការថ្លឹងថ្លែងអំពីភាពមិនម្ចាស់ការ និងភាពម្ចាស់ការ

កុមារចូលចិត្តធ្វើអ្វីដែលពួកគេទទួលអារម្មណ៍ថា ពួកគេមានសមត្ថភាព ។ កុមារដែលធំល្មមក្នុងការសម្គាល់ដឹងថា ខ្លួនគេជាក្មេងពិការភ្នែក គេក៏អាចសម្គាល់ដឹងថាក្មេងៗដទៃមានអាយុស្រករនឹងគេកំពុងធ្វើអ្វីៗ ដែលគេចូលចិត្តធ្វើផងដែរ តែគេមិនអាចធ្វើបាន ។ គេអាចមានអារម្មណ៍ខកចិត្ត ដែលភាពពិការភ្នែកមិនបើកឱកាសឱ្យគេមានម្ចាស់ការធ្វើអ្វីៗ ទៅតាមចំណង់ដែលគេចង់បាន ។




ចូរផ្តល់ភាពម្ចាស់ការដល់កូនឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបាន កាលណាគ្មានអ្វីដែលបង្កគ្រោះថ្នាក់ ធ្វើដូច្នេះគេរៀនធ្វើអ្វីៗកាន់តែច្រើនតាមដែលគេអាចធ្វើបានដោយខ្លួនឯង ។ កូនពិការភ្នែករបស់អ្នកត្រូវការមានលទ្ធភាពថែទាំខ្លួនឯង ដូចកុមារដទៃទៀតដែរ ។




ទោះបីនៅពេលគេធំហើយក៏ដោយ ពេលខ្លះកូនអ្នកនឹងស្នើសុំការជួយពីអ្នកណាម្នាក់ដែលមើលឃើញ ។ ចូរបង្រៀនកូនអ្នកថា មនុស្សគ្រប់គ្នាស្នើសុំការជួយម្តងម្កាលនៅពេលណាមួយ ។




ជួនកាលមនុស្សម្នាផ្តល់ការជួយនៅពេលដែលកុមារមិនចង់បាន ។ ចូរបង្រៀនកូនអ្នកថា ការទទួលយកការជួយគឺជាជំរើសរបស់នាង ។ នាងអាចនិយាយយ៉ាងសាមញ្ញថា "ទេ! ខ្ញុំអរគុណហើយ!" នៅពេលនាងមានអារម្មណ៍ថានាងអាចធ្វើអ្វីមួយដោយខ្លួនឯងបាន ។

## ការបន្តដោះស្រាយបញ្ហា

នៅពេលកូនអ្នកធំឡើង គេនឹងរកឃើញវិធីថ្មីៗដើម្បីពុះពារជំនះលើបញ្ហាទាំងឡាយ ។ ការសំខាន់ត្រូវចាំថា :-

អ្នកនិងកូនគឺជាមនុស្សជំនាញនៅពេលត្រូវដោះស្រាយរកវិធីធ្វើ**អ្វីៗដែលធ្វើឱ្យកូនមានការវិវត្តន៍ល្អ ។** អ្នកយល់ពីលទ្ធភាព និងបុគ្គលិកលក្ខណៈរបស់កូន ។ អ្នកនិងកូនមានវិធីដោះស្រាយបញ្ហាទាំងនោះ ។




ឥឡូវនេះកូនអ្នកធំហើយ គេអាចដោះស្រាយបញ្ហាខ្លះបានដោយខ្លួនឯង ។ គេអាចរិះគិតរកវិធីធ្វើអ្វីៗដោយខ្លួនឯងផ្ទាល់ ។




អ្នកដទៃទៀតដែលមិនអាចមើលឃើញច្បាស់បានរិះគិតរកឃើញវិធីពិសេសៗជាច្រើនអំពីការធ្វើអ្វីៗទាំងឡាយ ។ កូនរបស់អ្នកអាចរៀនអ្វីៗជាច្រើនទៀតដែលមានប្រយោជន៍ពីអ្នកដទៃទៀតដែលមិនអាចមើលឃើញច្បាស់ ។



## ការគិតអំពីអនាគត

ឥឡូវនេះកូនអ្នកមានអាយុទើបតែ 5 ឆ្នាំប៉ុណ្ណោះ តែ-ក្នុង ពេលឆាប់ៗខាងមុខ គេនឹងក្លាយជាក្មេងជំទង់ ហើយថ្ងៃណាមួយគេនឹងទៅជាមនុស្សពេញវ័យមួយរូប ។ អ្នកអាចជួយកូនឱ្យកំណត់គោលបំណងខ្ពស់សំរាប់ខ្លួនគេ ។ គេអាចធំឡើងក្លាយជាមនុស្សដែលម្ចាស់ការលើខ្លួនឯង ។ ចូរជួយកូនឱ្យមើលឃើញថាខ្លួនគេមានសមត្ថភាព ហើយមានឥរិយាបថសមរម្យអំពីការរៀនបំណិនជាច្រើនទៀត ។ ពួកគេធ្វើការងារ, រៀបអាពាហ៍ពិពាហ៍, មានកូន និងក្លាយជាឪពុកម្តាយដ៏ល្អ ។




## ការប្រើបទពិសោធន៍របស់អ្នកដើម្បីជួយដល់អ្នកដទៃទៀត

នៅពេលកូនធំឡើង ទាំងកូននិងអ្នកនឹងរៀនយ៉ាងច្រើនអំពីវិធីប្លែកៗគ្នាដែលកុមារពិការភ្នែកអាចរៀនធ្វើអ្វីៗ ការចែករំលែកបទពិសោធន៍របស់អ្នកជាមួយឪពុកម្តាយដែលមានទារកពិការភ្នែក ឬ ទារកដែលមិនអាចមើលឃើញច្បាស់នឹងក្លាយជាការជួយដ៏មានប្រយោជន៍បំផុតចំពោះឪពុកម្តាយទាំងនោះ ។







កូនធំៗរបស់អ្នកក៏អាចសំរេចចិត្តប្រើបទពិសោធន៍របស់គេជួយដល់ក្មេងៗពិការភ្នែក ឬ ដែលមិនអាចមើលឃើញច្បាស់ឯទៀតផងដែរ ។ វាជាការប្រសើរបំផុតដែលកុមារពិការភ្នែកចំណាយពេលជាមួយមនុស្សពេញវ័យដែលពិការភ្នែក ឬ មិនអាចមើលឃើញច្បាស់ ។

អ្នកប្រហែលជាអាចធ្វើការជាមួយអ្នកឯទៀតដើម្បីរៀបចំធ្វើឱ្យការគាំទ្រ និងផ្តល់សេវាកម្មសំរាប់ឪពុកម្តាយកុមារពិការភ្នែកឱ្យបានគ្រាន់បើជាងមុន។ ការដែលសំខាន់បំផុត អ្នកអាចធ្វើការផ្លាស់ប្តូរស្ថានភាពនៃភាពក្រីក្រ ធ្វើដូច្នេះនៅពេលអនាគតនឹងមិនសូវមានភាពពិការភ្នែក។




កូនប្រុស ឬ ស្រីពេញវ័យរបស់អ្នកអាចជ្រើសរើសធ្វើការងារជាមួយអ្នកដទៃទៀតដើម្បីធ្វើឱ្យកម្មវិធីសាលារៀន និង ឱកាសការងារសំរាប់កុមារ និងមនុស្សពេញវ័យដែលពិការភ្នែកបានប្រសើរឡើង។

